គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

# គោលការណ៍ណែនាំស្តីពី ការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន

## តើអ្វីជាគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន?

ជាឯកសារមគ្គុទ្ទេសក៍ ជំនួយស្មារតីសម្រាប់អង្គការសហគមន៍មូលដ្ឋាន ដើម្បីប្រតិបត្តិការនៅក្នុងសហគមន៍ប្រកបដោយអភិបាលកិច្ចល្អ វិជ្ជាជីវៈ និងនិរន្តរភាព។ គោលការណ៍នេះ ផ្តួចផ្តើម និងសម្របសម្រួលដោយអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក ឬ CCC) សហការជាមួយក្រុមការងារបច្ចេកទេសអង្គការសហគមន៍មូលដ្ឋាន និងការពិភាក្សាពិគ្រោះយោបល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាមួយភាគីពាក់ព័ន្ធនានា ជាពិសេសអង្គការសហគមន៍មូលដ្ឋាន។ គោលការណ៍នេះ ត្រូវបានបោះពុម្ពនៅឆ្នាំ២០១៧។




## គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក ឬ CCC)

គឺជាអង្គការសមាជិកភាព ដែលមានទាំងអង្គការជាតិ និងអង្គការអន្តរជាតិប្រមាណជា១៧០នៅកម្ពុជា។ អង្គការ គ.ស.ក ឬ CCC បានដើរតួនាទីយ៉ាងសំខាន់ចាប់តាំងពីឆ្នាំ១៩៩០មក ធ្វើការងារក្នុងភាពជាដៃគូដើម្បីពង្រឹងអភិបាលកិច្ចល្អ បរិយាកាសអំណោយផល និងនិរន្តរភាពអង្គការសង្គមស៊ីវិល សំរាប់ការអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយនិរន្តភាព។

## តើគោលការណ៍ណែនាំនេះមានអ្វីខ្លះ?

គោលការណ៍ណែនាំនេះមាន ៨ជំពូក អាចជួយអោយអង្គការសហគមន៍មូលដ្ឋានមានការប្រតិបត្តិល្អ ប្រសិទ្ធភាព និងមាននិរន្តរភាព ៖

- ជំពូកទី១៖ លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន
- ជំពូកទី២៖ ទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ
- ជំពូកទី៣៖ សមាជិកភាព និងការគ្រប់គ្រងសមាជិក
- ជំពូកទី៤៖ ការគ្រប់គ្រងហិរញ្ញវត្ថុ
- ជំពូកទី៥ ៖ គណនេយ្យភាព និងតម្លាភាព
- ជំពូកទី៦៖ ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ
- ជំពូកទី៧៖ យុទ្ធសាស្ត្រ និងការធានានិរន្តរភាព
- ជំពូកទី៨៖ ការពង្រឹងសមត្ថភាព និងការយល់ដឹង

## តើគោលការណ៍ណែនាំនេះផ្តល់ផលប្រយោជន៍អ្វីខ្លះដល់អង្គការសហគមន៍មូលដ្ឋាន?

គោលការណ៍ណែនាំនេះនឹងផ្តល់ប្រយោជន៍ជាច្រើនដល់អង្គការសហគមន៍មូលដ្ឋានដូចខាងក្រោម ៖

- ពង្រឹងសមត្ថភាពស្ថាប័ន
- គុណភាពសេវាកម្ម
- ប្រសិទ្ធភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ
- ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អជាមួយសមាជិកសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអាជ្ញាធរមូលដ្ឋាន
- លើកកម្ពស់ អភិបាលកិច្ចល្អ គណនេយ្យភាព តម្លាភាព និង
- ធានានូវនិរន្តរភាពរបស់អង្គការសហគមន៍មូលដ្ឋាន

ផលប្រយោជន៍ខាងលើ នឹងជម្រុញអោយអង្គការសហគមន៍មូលដ្ឋានចូលរួមចំណែកយ៉ាងមានប្រសិទ្ធភាពក្នុងការលើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋសហគមន៍ខ្លួនឯងផ្ទាល់ ក៏ដូចជាការចូលរួមអភិវឌ្ឍសង្គមជាតិទាំងមូល។

# តើធ្វើដូចម្តេចដើម្បីអោយអង្គការសហគមន៍មូលដ្ឋានអាចប្រើប្រាស់គោលការណ៍នេះប្រកបដោយប្រសិទ្ធភាព?

## វគ្គបណ្តុះបណ្តាលគ្រូបង្គោល និងវគ្គបណ្តុះបណ្តាលទូទៅ៖

អង្គការសហគមន៍មូលដ្ឋានអាចចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល និងវគ្គបណ្តុះបណ្តាលទូទៅ ឬអាចយកកម្រងឯកសារខាងក្រោមនេះទៅប្រើប្រាស់ដោយខ្លួនឯងបាន។




## ការរៀនសូត្រតាមប្រព័ន្ធអ៊ីនធឺណេត




អង្គការសហគមន៍មូលដ្ឋានអាចសិក្សាតាមប្រព័ន្ធរៀនសូត្រតាមអ៊ីនធឺណេតដោយចូលទៅកាន់

http://cbo.gpp-cambodia.org

## ការរៀនសូត្រតាម Facebook Group




អង្គការសហគមន៍មូលដ្ឋានអាចចូលជាសមាជិករបស់ **Facebook Group**

https://www.facebook.com/groups/CambodiaCBO/

# តើធ្វើដូចម្តេចដើម្បីទទួលបានសៀវភៅគោលការណ៍ណែនាំនេះ?

ផ្ទះលេខ៩-១១ ផ្លូវលេខ៤៧៦ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ៖ (៨៥៥ ២៣) ២១៤ ១៥២/ **០៦១ ៨២៨ ១៣៦**
ទូរសារ៖ (៨៥៥ ២៣) ២១៦ ០០៩
សារអេឡិចត្រូនិច៖ cboccc2018@gmail.com
គេហទំព័រ៖ www.ccc-cambodia.org